# សេចក្ដីណែនាំចាប់ផ្ដើមរហ័ស
## ការបង្រៀនវគ្គសិក្សាមូលដ្ឋានគ្រឹះថ្នាក់វិទ្យាស្ថាន

### ពីមុនការបង្រៀន

- សូមសិក្សាបុព្វកថានៅក្នុងសម្ភារសម្រាប់គ្រូបង្រៀនដោយយកចិត្តទុកដាក់ ។
- សូមរៀបចំពេលវេលាជាមួយអ្នកសម្របសម្រួល ឬនាយកថ្នាក់វិទ្យាស្ថាន ដើម្បីពិភាក្សាអំពីការចាត់តាំងរបស់អ្នក សិស្ស វគ្គសិក្សា និងសំណួរដែលអ្នកមាន ។
- សូមអធិស្ឋានសម្រាប់ការណែនាំដើម្បីជួយសិស្សរបស់អ្នកឲ្យមកឯព្រះគ្រីស្ទ និងកាន់តែប្រែក្លាយដូចទ្រង់ ។

### ទិដ្ឋភាពទូទៅនៃវគ្គសិក្សាមូលដ្ឋានគ្រឹះ

- វគ្គសិក្សាមូលដ្ឋានគ្រឹះត្រូវបានរចនាឡើងដើម្បីជួយសិស្សឲ្យមានបទពិសោធន៍នៃការផ្លាស់ប្រែចិត្តជឿ មុនពេល អំឡុងពេល និង បន្ទាប់ពីការពិភាក្សាក្នុងថ្នាក់ ។
- មេរៀននីមួយៗ មានទាំងសម្ភាររៀបចំ និងសម្ភារបង្រៀនសម្រាប់គ្រូបង្រៀន ។
  - **សម្ភាររៀបចំ ៖** ត្រូវបានរចនាឡើង ដើម្បីរៀបចំទាំងអ្នកផង និងសិស្សរបស់អ្នកផង សម្រាប់ថ្នាក់ ជាមួយនឹងព័ត៌មានប្រវត្តិ ព្រះគម្ពីរ ការបង្រៀនមកពីថ្នាក់ដឹកនាំសាសនាចក្រ ការបំផុសនានាដែលអញ្ជើញឲ្យមានការរៀនសូត្រកាន់តែជ្រាលជ្រៅ និងធនធានបន្ថែមសម្រាប់ការសិក្សាបែមទៀត ។
  - **សម្ភារសម្រាប់គ្រូបង្រៀន ៖** ត្រូវបានរចនាឡើង ដើម្បីជួយអ្នកអញ្ជើញសិស្សឲ្យចែកចាយ និងពិភាក្សាអំពីអ្វីដែលពួកគេបានរៀន នៅក្នុងការរៀបចំរបស់ពួកគេ និងជួយសិស្សឲ្យមានការយល់ដឹងកាន់តែស៊ីជម្រៅ និងទីបន្ទាល់របស់ពួកគេរឹងមាំ អំពីព្រះអម្ចាស់ និងដំណឹងល្អរបស់ទ្រង់ដែលបានស្ដារឡើងវិញ និង អញ្ជើញពួកគេឲ្យអនុវត្តតាម ។
- ត្រូវដឹងអំពីគោលបំណងមកតាមក្រោយនៃលទ្ធផលសំខាន់ៗ នៃវគ្គសិក្សា នៅពេលដែលអ្នកផ្ដោតការយកចិត្តទុកដាក់ទៅលើបទពិសោធន៍ការរៀនសូត្ររបស់សិស្សដែលមិនគ្រាន់តែជាការបង្រៀនមេរៀនប៉ុណ្ណោះទេ ។

#### រៀបចំ

- សិស្ស និង គ្រូរៀបចំសម្រាប់ថ្នាក់តាមរយៈ បទពិសោធន៍នៃការរៀបចំដែលត្រូវបានណែនាំមួយ ។
- សម្ភាររៀបចំជួយឲ្យការសិក្សារបស់សិស្ស កាន់តែស៊ីជម្រៅ និងរៀបចំពួកគេ ឲ្យចែកចាយអ្វីដែលពួកគេបានរៀននៅក្នុងថ្នាក់ ។

#### រួមចំណែក

- គ្រូទាំងឡាយពឹងផ្អែកទៅលើការរៀបចំរបស់សិស្ស ដើម្បីធ្វើឲ្យសិស្សកាន់តែចូលរួម នៅក្នុងបទពិសោធន៍ការរៀនសូត្រ និងដើម្បីជួយឲ្យការរៀនសូត្ររបស់ពួកគេកាន់តែស៊ីជម្រៅ ។
- ការរៀបចំ និងការចូលរួមចំណែករបស់សិស្ស ធ្វើឲ្យថ្នាក់មានបន្ថែមទៀតដើម្បីពិភាក្សា និងសង្កត់ធ្ងន់លើការអនុវត្ត ។

#### អនុវត្ត

- សិស្សត្រូវបានអញ្ជើញឲ្យពិចារណាពីរបៀបដែលពួកគេអនុវត្តចំពោះអ្វីដែលពួកគេបានរៀន ហើយបន្ទាប់មកអនុវត្តវា ។
- ការសង្កត់ធ្ងន់លើការចូលរួមចំណែក និងលើការអនុវត្តជួយសិស្ស នៅក្នុងការខិតខំរបស់ពួកគេក្នុងគោលបំណងប្រែក្លាយកាន់តែដូចព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ ។

### បទពិសោធន៍នៃការអនុវត្តជាក់ស្ដែងជាបន្តបន្ទាប់

- អ្នកនឹងមានឱកាសជាបន្តបន្ទាប់ជាមួយអ្នកសម្របសម្រួល ឬនាយកថ្នាក់វិទ្យាស្ថាន ដើម្បីពិភាក្សាអំពីអ្វីដែលអ្នកកំពុងរៀនសូត្រ សួរសំណួរអំពីការចាត់តាំងរបស់អ្នក និងអនុវត្តការកែលម្អការបង្រៀនរបស់អ្នក ។
- អ្នកអាចប្រើក្បួនខ្នាត និងការបំពាក់បំប៉នថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ដើម្បីដឹកនាំអ្នក នៅពេលដែលអ្នករៀនអំពីគោលការណ៍ និងអនុវត្តជំនាញដែលអាចជួយអ្នកកែលម្អក្នុងនាមជាគ្រូបង្រៀន ។



© 2020 by Intellectual Reserve, Inc. All rights reserved. កំណែថ្មី ៖ ៤/២០ PD60011179 258